# ពិធីប្រទានពរផ្ទះថ្មី

## ១ - ពិធីប្រារព្ធ

បទចម្រៀងចូល **យើងទៅដំណាក់ព្រះអង្គ** (ទំព័រ ១៣៥)

ប. **ក្នុងព្រះនាមព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ ។**

គ្រ. អាម៉ែន ។

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ្រ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង ។

ប. ផ្ទះរបស់គ្រីស្តបរិស័ទ ជាព្រះដំណាក់របស់ព្រះជាម្ចាស់ ។
នៅថ្ងៃនេះ យើងមកជួបជុំគ្នានៅទីនេះ ក្នុងជំនឿតែមួយ ។
ឥឡូវនេះ យើងប្រកាសជំនឿរបស់ព្រះសហគមន៍ទាំងមូល៖

## ២ - ធម៌ប្រកាសជំនឿរបស់គ្រីស្តទូត

ខ្ញុំជឿលើព្រះជាម្ចាស់ ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ជាព្រះបង្កើតមេឃ និងដី ។ ខ្ញុំជឿលើព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាតែមួយនៃព្រះបិតា ហើយជាព្រះអម្ចាស់យើងខ្ញុំ ។ ព្រះអង្គមានកំណើតជាមនុស្ស ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទ្រង់បានប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី ព្រះអង្គបានសោយទុក្ខលំបាកនៅជំនាន់ លោកប៉ុនពីឡាត ។ ព្រះអង្គត្រូវគេឆ្កាង

សោយទិវង្គត ហើយព្រះសពព្រះអង្គ ត្រូវគេបញ្ចុះក្នុងរូងថ្មមួយ ។ ព្រះអង្គបានយាងចុះទៅស្ថានក្រោម លុះដល់ថ្ងៃទីបី ព្រះអង្គមានព្រះជន្មរស់ឡើងវិញ ពីចំណោមមនុស្សស្លាប់ ព្រះអង្គបានយាងឡើងស្ថានបរមសុខ ទៅគង់ខាងស្តាំព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ។ ព្រះអង្គនឹងយាងមកវិញ ដើម្បីវិនិច្ឆ័យមនុស្សទាំងរស់ ទាំងស្លាប់ ។ ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ ខ្ញុំជឿលើព្រះសហគមន៍កាតូលិកដ៏វិសុទ្ធ និងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ ។ ខ្ញុំជឿថា មានការលើកលែងទោសមនុស្សឲ្យរួចពីបាប ហើយរូបកាយមនុស្សនឹងរស់ឡើងវិញ ព្រមទាំងមានជីវិតរស់នៅអស់កល្បជានិច្ចផង ។ **អាម៉ែន ។**

# ៣ - ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

**អត្ថបទទី១៖ សូមថ្លែងលិខិតទីមួយរបស់សន្ត សិលា** (១,៣-៩;២,៤-៥)

សូមសរសើរតម្កើងព្រះជាម្ចាស់ ជាព្រះបិតារបស់ព្រះយេស៊ូគ្រីស្ត ជាព្រះអម្ចាស់នៃយើង ។ ព្រះជាម្ចាស់បានប្រោសយើងអោយកើតជាថ្មី ដោយប្រោសព្រះយេស៊ូគ្រីស្តអោយមានព្រះជន្មរស់ឡើងវិញ ស្របតាមព្រះហឫទ័យមេត្តាករុណាដ៏លើសលប់របស់ព្រះអង្គ ដូច្នេះ យើងមានសេចក្តីសង្ឃឹមដែលមិនចេះសាបសូន្យ ហើយយើងនឹងទទួលមត៌កដែលមិនចេះរលួយ មិនចេះសៅហ្មង មិនចេះស្រពោន ។ ព្រះជាម្ចាស់បម្រុងទុកមត៌កនេះអោយបងប្អូននៅស្ថានបរមសុខ ហើយឫទ្ធានុភាពរបស់ ព្រះអង្គថែរក្សាបងប្អូនដោយសារជំនឿ ដើម្បីអោយបងប្អូនទទួលការសង្គ្រោះ ដែលព្រះអង្គបានរៀបចំទុកជាស្រេច ហើយដែលទ្រង់នឹងសំដែងនៅគ្រាចុងក្រោយបំផុត ។ ហេតុនេះ ហើយ បាន



គេចេះសំដែងសេចក្តីមេត្តាករុណាដល់បងប្អូនជិតខាង សូមឲ្យសេចក្តីសុខសាន្តស្ថិតនៅក្នុងផ្ទះនេះ ហើយជាមួយបងប្អូនអ្នកជិតខាងផង ។ យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ ។ **អាម៉ែន ។**

ប. សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។

គ. ហោយគង់ជាមួយវិញ្ញាណរបស់លោកផង ។

ប. សូមឲ្យសេចក្តីសុខសាន្តរបស់ព្រះគ្រីស្តសោយរាជ្យនៅក្នុងចិត្ត របស់បងប្អូនជានិច្ច ។

គ. អាមែន ។

ប. សូមឲ្យពាក្យសម្តី និងគ្រប់សកម្មភាពរបស់យើងខ្ញុំ កើតចេញជារូបរាងក្នុងព្រះនាមរបស់ព្រះអង្គរៀងរាល់ពេលវេលា ។

គ. អាមែន ។

ប. សូមព្រះដ៏មានឫទ្ធានុភាពសព្វប្រការគឺ ✠ ព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ប្រទានពរដល់អស់បងប្អូន ។

គ. អាមែន ។

ប. សូមអស់បងប្អូនអញ្ជើញឲ្យបានសុខសាន្ត ។

គ. សូមអរព្រះគុណព្រះជាម្ចាស់ ។

**ចម្រៀងគោរពព្រះនាងម៉ារី៖ អាវេ ម៉ារីយ៉ា** (ទំព័រ ២៤៨)

ព្រះអង្គបានប្រទានទឹកដែលផ្តល់ជីវិតមកឲ្យមនុស្សលោក ។ សូមព្រះអង្គ ប្រទានព្រះពរលើទឹកនេះ ✠ ឲ្យជួយរំលឹកនូវ ព្រះអំណោយទាន ដែលយើងបានទទួលក្នុងឱកាសអគ្គសញ្ញាជ្រមុជទឹក ។ សូមឲ្យទឹកនេះ បានទៅជាសញ្ញានៃការប្រទានព្រះពររបស់ព្រះអង្គចំពោះផ្ទះនេះផង ។ យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូ ជាព្រះគ្រិស្ត និងជាអម្ចាស់យើងខ្ញុំ ។ **អាម៉ែន ។**

ម្នាក់ៗយកដៃជ្រលក់ក្នុងផ្តិលទឹក រូបគូសសញ្ញាព្រះឈើឆ្កាង ។ លោកបូជាចារ្យជាមួយម្ចាស់ផ្ទះទៅបាចទឹកព្រះពរក្នុងបន្ទប់នីមួយៗនៃផ្ទះ ។

# ៨ - ពិធីគោរពព្រះឈើឆ្កាង

អស់អ្នកដែលចូលរួមនៅក្នុងពិធីនេះ គោរពព្រះឈើឆ្កាងដូចតទៅនេះ ៖

ប. នេះជាឈើដែលគេឆ្កាងព្រះយេស៊ូគ្រីស្ត គេបានធ្វេគុតព្រះសង្គ្រោះមនុស្សលោក នៅលើឈើនេះ

គ. យើងខ្ញុំសូមក្រាបថ្វាយបង្គំព្រះឈើឆ្កាង ។

# ៩ - អធិដ្ឋានបញ្ចប់

ប. សូមបងប្អូនតាំងចិត្តអធិដ្ឋាន ។

បពិត្តព្រះបិតាប្រកបដោយឫទានុភាពសព្វប្រការ

សូមព្រះអង្គប្រោសប្រទានពរដល់ផ្ទះនេះ ឲ្យអស់អ្នកដែលរស់នៅក្នុងផ្ទះនេះ បានសេចក្តីសុខសាន្ត និងមានជំនឿកាន់តែមាំមួនឡើងៗ ។ សូមឲ្យ



ជាបងប្អូនមានចិត្តរីករាយយ៉ាងខ្លាំង ទោះបីពេលនេះ បងប្អូនព្រួយចិត្តដោយជួបនឹងទុក្ខលំបាកផ្សេងៗ ក្នុងមួយរយៈពេលខ្លីក៏ដោយ ។ ទុក្ខលំបាកទាំងនេះនឹង លត់ដំជំនឿរបស់បងប្អូន អោយមានតម្លៃលើសមាស ដែលតែងតែរលាយសូន្យនោះទៅទៀត គឺមាសដែលសំរាំងក្នុងភ្លើង ។ នៅថ្ងៃដែលព្រះយេស៊ូគ្រីស្តសំដែងខ្លួនអោយមនុស្សលោកឃើញជំនឿរបស់បងប្អូននឹងទទួលការសរសើរ ទទួលសិរីរុងរឿង និងកិត្តិយសជាមិនខាន ។ បងប្អូនមិនដែលបានឃើញព្រះអង្គទេ តែបងប្អូនស្រឡាញ់ព្រះអង្គ ទោះបីបងប្អូននៅតែពុំទាន់ឃើញព្រះអង្គក្តី ក៏បងប្អូនជឿលើព្រះអង្គ ហើយមានអំណរសប្បាយដ៏រុងរឿងរកថ្លែងពុំបាន ព្រោះបងប្អូនបានទទួលការសង្គ្រោះ សំរាប់ព្រលឹងខ្លួន ដែលជាទីដៅនៃជំនឿរបស់បងប្អូន ។ ហេតុនេះ សូមបងប្អូនចូលមកជិតព្រះគ្រីស្ត ជាសិលាដ៏មានជីវិត ជាសិលាដែលមនុស្សលោកបានបោះបង់ចោល តែព្រះជាម្ចាស់បានរើសយក ព្រោះទ្រង់ឈ្វេងយល់ថាមានតម្លៃវិសេស ។ រីឯបងប្អូនវិញ បងប្អូនប្រៀបបាននឹងថ្មដ៏មានជីវិតដែរ ដូច្នេះចូរផ្គុំគ្នាឡើងកសាងជាព្រះដំណាក់របស់ព្រះវិញ្ញាណ ធ្វើជាក្រុមបូជាចារ្យដ៏វិសុទ្ធ ដើម្បីថ្វាយយញ្ញបូជាខាងវិញ្ញាណ ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ តាមរយៈព្រះយេស៊ូគ្រីស្ត ។

ប. នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ។ គ្រ. សូមអរព្រះគុណព្រះជាម្ចាស់ ។

## ទំនុកតំកើងលេខ ១២៧(១២៦) បទពាក្យ ៧

១- ប្រសិនបើព្រះជាអម្ចាស់ មិនជួយសង់ផ្ទះនោះទេណា
អ្នកសង់ខំប្រឹតឥតបានការ គឺគ្មានវាសនាខ្វះលំនឹង ។
បើព្រះអម្ចាស់មិនរក្សា ទីក្រុងទេណាឲ្យរឹងប៉ឹង
អ្នកយាមទីក្រុងដែលខំប្រឹង យាមរាល់ថ្ងៃហ្នឹងអត់អសារ ។

២- អ្នករាល់គ្នាក្រោកពីព្រលឹម   រកស៊ីចិញ្ចឹមជនជីវ៉ា
ខំទាំងលំបាកគ្រប់កាយា   តែឥតបានការផលចំណេញ ។
ព្រះជាអម្ចាស់បានប្រទាន   អាហារធនធានច្រើនពាសពេញ
ដល់អ្នកដែលព្រះអង្គស្រឡាញ់   ក្នុងពេលយប់យន់គេនិទ្រា ។

**រដូវធម្មតា**

**អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!**

ឱ! ព្រះបិតាអើយ សូមឲ្យអស់អ្នកជឿលើទូលបង្គំ រួមគ្នាជាធ្លុងតែមួយ ដើម្បីឲ្យមនុស្សលោកដឹងថាព្រះអង្គបានចាត់ទូលបង្គំឲ្យមកមែន ។

**អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!**

**រដូវអប់រំពិសេស**

**សូមលើកតម្កើងសិរីរុងរឿងព្រះគ្រីស្ត ព្រះអង្គជាព្រះពន្លឺនៃព្រះជាម្ចាស់ សូមកោតសរសើរព្រះអង្គ ។**

ឱ! ព្រះជាម្ចាស់ សូមព្រះមេត្តា អាណិតអាសូរ កែប្រែដួងចិត្ត គំនិតយើងខ្ញុំ ដើម្បីទទួលព្រះសង្គ្រោះយើង ។

ប. ✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** ៧,២១-២៩

«អ្នកដែលចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ មិនមែនជាអ្នកដែលគ្រាន់តែហៅខ្ញុំថា “ព្រះអម្ចាស់! ព្រះអម្ចាស់!” ប៉ុណ្ណោះទេ គឺជាអ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាខ្ញុំ ដែលគង់នៅស្ថានបរមសុខនោះវិញ ។ នៅថ្ងៃនោះ នឹងមានមនុស្សជាច្រើនពោលមកខ្ញុំថា “ព្រះអម្ចាស់ ព្រះអម្ចាស់អើយ! យើងខ្ញុំធ្លាប់ថ្លែងព្រះបន្ទូលក្នុងព្រះនាមព្រះអង្គ យើងខ្ញុំធ្លាប់ដេញអារក្សក្នុងព្រះនាមព្រះអង្គ ហើយយើងខ្ញុំក៏ធ្លាប់ធ្វើការអស្ចារ្យជាច្រើន



**ដ្បិតព្រះអង្គគ្រងរាជ្យ ទ្រង់មានឫទ្ធានុភាព និងសិរីរុងរឿងអស់កល្បជាអង្វែងតរៀងទៅ។ អាម៉ែន។**

## ៦ - ពាក្យអង្វរសូមព្រះជាម្ចាស់ប្រទានព្រះពរ

លោកបូជាចារ្យទ្រាប់ដៃទទួលអង្វរព្រះអង្គថា ៖

ប. បពិត្រព្រះបិតាជាអម្ចាស់!
សូមព្រះអង្គព្រះសណ្ដាប់ពាក្យអង្វររបស់អ្នកបម្រើព្រះអង្គ
ដែលជួបជុំគ្នានៅថ្ងៃនេះ ក្នុងផ្ទះនេះ ។
សូមឲអស់បងប្អូនដែលស្នាក់នៅទីនេះ
បានទទួលជម្រកក្នុងអង្គព្រះគ្រិស្ត ។
នៅពេលបងប្អូនចេញពីផ្ទះនេះ សូមព្រះអង្គគង់នៅជាមួយពួកគាត់ ក្នុងពេលធ្វើដំណើរ ។ នៅពេលត្រឡប់មកផ្ទះនេះវិញ សូមព្រះអង្គទទួលស្វាគមន៍ពួកគាត់នៅក្នុងផ្ទះនេះ រហូតដល់ថ្ងៃដែលគេនឹងរស់នៅក្នុងព្រះដំណាក់របស់ព្រះបិតា នៅឯស្ថានបរមសុខផង ។
យើងខ្ញុំសូមអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រិស្ត និងជាអម្ចាស់យើងខ្ញុំ ។ **អាម៉ែន ។**

## ៧ - ពិធីបាចទឹកព្រះពរ

ប. បពិត្រព្រះបិតាជាអម្ចាស់យើងខ្ញុំ
ព្រះអង្គជាប្រភពនៃជីវិត និងជាប្រភពនៃវិសុទ្ធភាពគ្រប់យ៉ាង ។

ចាប់របស់អ្នកដទៃផង ។

- សូមព្រះអង្គប្រទានឲប្រទេសកម្ពុជាយើង នូវយុត្តិធម៌ និងសុខសន្តិភាព ។
- សូមព្រះអង្គជួយឲ្យអស់អ្នកដែលនៅឆ្ងាយពីទឹកដី ពីផ្ទះ ពីក្រុមគ្រួសាររបស់ខ្លួន បានប្រកបដោយសេចក្ដីសុខសាន្ត ។
- សូមព្រះអង្គជួយឲ្យផ្ទះរបស់យើងខ្ញុំ បានទៅជាកន្លែងស្វាគមន៍ដ៏កក់ក្ដៅចំពោះមនុស្សទាំងអស់ ។

## ៥ - ធម៌ឱព្រះបិតា

ប. តាមដំបូន្មានរបស់ព្រះយេស៊ូជាព្រះសង្គ្រោះ និងតាមការប្រៀនប្រដៅរបស់ព្រះអង្គ យើងខ្ញុំហ៊ានទូលថា ៖

**ឱ ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !**
**សូមសម្ដែងព្រះបារមីឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ**
**សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់**
**សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ បានសម្រេចនៅលើផែនដី**
**ដូចនៅស្ថានបរមសុខដែរ។**
**សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។**
**សូមអត់ទោសឲ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នក**
**ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។**
**សូមកុំបណ្ដោយឲ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ។**
**តែសូមរំដោះយើងខ្ញុំ ឲ្យរួចពីមារកំណាច។**



ក្នុងព្រះនាមព្រះអង្គដែរ” ។ ពេលនោះ ខ្ញុំនឹងប្រកាសប្រាប់អ្នករាល់គ្នាថា “ពួកអ្នកប្រព្រឹត្តអំពើទុច្ចរិតអើយ! ចូរថយចេញអោយឆ្ងាយពីខ្ញុំទៅ ខ្ញុំមិនដែលស្គាល់អ្នករាល់គ្នាទេ!” » ។

«អ្នកណាស្ដាប់ពាក្យ ខ្ញុំនេះ ហើយប្រព្រឹត្តតាម អ្នកនោះប្រៀបបានទៅនឹងមនុស្សឈ្លាសវៃម្នាក់ ដែលបានសង់ផ្ទះរបស់ខ្លួននៅលើផ្ទាំងថ្ម ។ ទោះបីភ្លៀងបង្អុរ ចុះមក ហើយមានទឹកជន់ មានខ្យល់បក់បោកប៉ះនឹងផ្ទះនោះយ៉ាងណាក៏ដោយ ក៏ផ្ទះនោះមិនរលំដែរ ព្រោះមានគ្រឹះនៅលើផ្ទាំងថ្ម ។ រីឯអ្នកដែលស្ដាប់ពាក្យខ្ញុំនេះ តែមិនប្រព្រឹត្តតាម ប្រៀបបានទៅនឹងមនុស្សឆោតល្ងង់ម្នាក់ ដែលបានសង់ផ្ទះរបស់ខ្លួននៅលើដីខ្សាច់ ពេលភ្លៀងបង្អុរចុះមក ហើយមានទឹកជន់មានខ្យល់បក់បោកប៉ះនឹងផ្ទះនោះ ផ្ទះនោះរលំបាក់បែកខ្ទេចអស់គ្មានសល់» ។ កាលព្រះយេស៊ូមានព្រះបន្ទូលទាំងនេះចប់សព្វគ្រប់ហើយ មហាជនងឿងឆ្ងល់យ៉ាងខ្លាំងអំពីសេចក្ដីដែលព្រះអង្គប្រៀនប្រដៅ ព្រោះព្រះអង្គមានព្រះបន្ទូលប្រកបដោយអំណាច ខុសប្លែកពីពួកអាចារ្យរបស់ពួកគេ ។

ប. នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

គ្រ. សូមកោតសរសើរព្រះអម្ចាស់យេស៊ូគ្រីស្ត ។

## ៤ - ពាក្យអង្វរសកល

**បន្ទរ៖ ឱ! ព្រះអម្ចាស់អើយ សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់ ។**

១. សូមបងប្អូនអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រោសប្រទានពរដល់អ្នក ដែលរស់នៅក្នុងផ្ទះនេះ បានសេចក្ដីសុខ ទាំងផ្លូវកាយ ទាំងផ្លូវចិត្តផង ។

២. សូមឲ្យអំណាចរបស់មារឃ្លាតឆ្ងាយពីផ្ទះនេះ សូមឲ្យចិត្តរបស់អ្នកដែលរស់នៅក្នុងផ្ទះនេះ ព្រមទទួលសេចក្ដីត្រូវការរបស់អ្នកជិតខាងផង ។

៣. សូមឲ្យអ្នកដែលរស់នៅក្នុងផ្ទះនេះ ចេះស្រឡាញ់គ្នាទៅវិញទៅមក ចេះអត់ឱនឲ្យគ្នា ហើយចេះរួបរួមគ្នាជាធ្លុងតែមួយ ក្នុងអង្គព្រះគ្រីស្ត ។

៤. សូមឲ្យអ្នកដែលរស់នៅក្នុងផ្ទះនេះ មានជំនឿកាន់តែមាំមួនឡើងៗ ហើយប្រព្រឹត្តគំរូល្អ ដោយបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ផង ។

៥. សូមព្រះជាម្ចាស់ប្រោសប្រទានពរដល់ការងាររបស់អ្នកដែលរស់នៅក្នុងផ្ទះនេះ ឲ្យបានរីកចំរើន តាមព្រះហឫទ័យព្រះអង្គផង ។

ឬ

ព្រះបុត្រារបស់ព្រះជាម្ចាស់ ជាព្រះជាម្ចាស់នៃស្ថានលើ និងស្ថានក្រោម ព្រះអង្គបានចាប់កំណើតជាមនុស្ស និងគង់នៅក្នុងចំណោមយើងខ្ញុំ ។ ដោយអំណរសប្បាយ យើងខ្ញុំសូមទូលអង្វរព្រះអង្គថា ៖

**បន្ទរ៖ ឱ! ព្រះអម្ចាស់អើយ សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់ ។**

១. ព្រះអង្គបានប្រោសឲ្យផ្ទះនៃភូមិណាសារ៉ែត ជាមួយព្រះនាងម៉ារី និងលោកយ៉ូសែប បានទៅជាវិសុទ្ធ ។ សូមព្រះអង្គគង់នៅក្នុងផ្ទះនេះ ជាភ្ញៀវរបស់យៀង និងជាព្រះជាម្ចាស់របស់យើងទៀតផង ។

២. ដោយសារតែព្រះអង្គ ទីលំនៅទាំងអស់រីកដុះឡើង ទៅជាព្រះដំណាក់របស់ព្រះជាម្ចាស់ ។ សូមព្រះអង្គប្រោសឲ្យអស់ អ្នកដែលរស់នៅក្នុងផ្ទះនេះ បានទៅជាព្រះដំណាក់របស់ព្រះជាម្ចាស់ក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ។

៣. ព្រះអង្គសព្វព្រះហឫទ័យឲ្យអស់អ្នកជឿ កសាងផ្ទះរបស់ខ្លួនលើផ្ទាំងថ្មដ៏រឹងមាំនៃជំនឿ ។ សូមឲ្យក្រុមគ្រួសារនៅក្នុងផ្ទះនេះ បានពឹងផ្អែកលើព្រះបន្ទូលរបស់ព្រះអង្គ និងបម្រើព្រះអង្គដោយចិត្តសប្បុរសផង ។



៤. នៅពេលព្រះអង្គគង់នៅលើផែនដីនេះ មិត្តសម្លាញ់ទាំងប៉ុន្មានរបស់ព្រះអង្គបានទទួលព្រះអង្គដោយអំណរសប្បាយ ។ សូមព្រះអង្គជួយយើង និងនាំឲ្យយើង ចេះជួយអស់អ្នកគ្មានទីជម្រក ។

សូមសន្តបុគ្គលទាំងឡាយ ជួយអង្វរព្រះអម្ចាស់ឲយើងខ្ញុំ

**បន្ទរ៖ សូមព្រះអង្គមេត្តាប្រោសស្តាប់យើងខ្ញុំ**

- ឱ! ព្រះយេស៊ូជា ព្រះបុត្រានៃព្រះជាម្ចាស់ ដែលគង់នៅជាដរាប ។
- ព្រះអង្គដែលបានយាងមកគង់នៅក្នុងចំណោមយើងខ្ញុំ ។
- ព្រះអង្គដែលបានរស់នៅ ជាមួយព្រះនាងម៉ារីនិងលោកយ៉ូសែប នៅក្នុងផ្ទះ ភូមិណាសារ៉ែត ។
- ព្រះអង្គដែលស្នាក់នៅក្នុងផ្ទះលោក ស៊ីម៉ូនសិលា ។
- ព្រះអង្គដែលបានយាងចូលក្នុងផ្ទះអ្នកបាប ។
- ព្រះអង្គដែលបានស្នាក់នៅក្នុងផ្ទះលោកឡាសារ នាងមាថា និងនាងម៉ារី ។
- សូមព្រះអង្គគង់នៅជាមួយបងប្អូននៅក្នុងផ្ទះនេះ និងណែនាំពួកគាត់តាមមាគ៌ារបស់ ព្រះអង្គជានិច្ចផង ។
- សូមព្រះអង្គជួយការពារយើងខ្ញុំ ឲ្យបាកផុតពីសេចក្តីវិនាស និងសូមព្រះអង្គបើក ចិត្តគំនិតរបស់យើងខ្ញុំ ឲ្យចេះទទួលស្គាល់ទុក្ខលំបាក និងការឈឺ